**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**នាយកដ្ឋានព័ត៌មាន**

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលនៃទស្សនកិច្ចការងាររបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋប្រជាមានិតចិន
# ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០២០

--------

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលមួយចំនួន បានបញ្ចប់ដោយជោគជ័យនូវដំណើរបំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋប្រជាមានិតចិន នាល្ងាចថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០២០ ដោយបានជួបពិភាក្សាជាមួយ **ឯកឧត្តម នាយករដ្ឋមន្ត្រី លី ខឺឈាង** និង ជួបសម្តែងការគួរសមជាមួយ **ឯកឧត្តម ប្រធានាធិបតី ស៊ី ជីនពីង** នៅទីក្រុងប៉េកាំង។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជម្រាបជូនថ្នាក់ដឹកនាំចិនថាទស្សនកិច្ចនេះមានគោលបំណងសំខាន់ចំនួន៣គឺ (១) បង្ហាញនូវសាមគ្គីភាព រួមសុខរួមទុក្ខជាមួយរដ្ឋាភិបាលចិន ក៏ដូចជាប្រជាពលរដ្ឋចិននៅក្នុងគ្រាដ៏លំបាក (២) ពង្រឹងស្មារតីនិងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ និងនិស្សិតកម្ពុជា ឲ្យបន្តស្នាក់នៅប្រទេសចិន ខណៈដែលអាជ្ញាធរចិនកំពុងអនុវត្តវិធានការម៉ឺងម៉ាត់ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបង្កឡើងដោយការរាលដាលវីរុសកូរ៉ូណា និង(៣) បញ្ជូនសារទៅប្រជាពលរដ្ឋកម្ពុជា កុំឲ្យមានជម្ងឺភ័យខ្លាចហួសហេតុ ជាងកំរិតនៃគ្រោះថ្នាក់បង្កឡើងដោយវីរុសកូរ៉ូណា ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានចូលរួមរំលែកទុក្ខ និងសម្តែងនូវសមានចិត្តសោកស្តាយចំពោះការបាត់បង់ជីវិតប្រជាជនដោយសារការឆ្លងវីរុសកូរ៉ូណា ហើយបានគូសបញ្ជាក់អំពីការគាំទ្រ និងកោតសរសើររដ្ឋាភិបាលចិន ដែលបានចាត់វិធានការត្រឹមត្រូវ និងមានប្រសិទ្ធភាព ដើម្បីព្យាបាលអ្នករងគ្រោះ និងទប់ស្កាត់ការរាលដាលជម្ងឺនេះទៅតំបន់នានាទាំងនៅក្នុងប្រទេសចិន ក៏ដូចជានៅទូទាំងពិភពលោក។ **សម្តេចតេជោ** បានថ្លែងអំណរគុណចំពោះអាជ្ញាធរចិនដែលបាន និងបន្តយកចិត្តទុកដាក់ចំពោះសុវត្ថិភាព សុខភាព និងការស្នាក់នៅរបស់ប្រជាជន និងនិស្សិតខ្មែរនៅគ្រប់តំបន់ក្នុងប្រទេសចិន។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 541
អ៊ីម៉ែល : mfaic@mfaic.gov.kh

**ឯកឧត្តម នាយករដ្ឋមន្ត្រី លី ខឺឈាង** ក៏ដូចជា **ឯកឧត្តម ប្រធានាធិបតី ស៊ី ជីនពីង** បានថ្លែងអំណរគុណចំពោះកាយវិការ សាមគ្គីភាព និងទឹកចិត្តរួមសុខទុក្ខរបស់កម្ពុជា ជាមួយរដ្ឋាភិបាល និងប្រជាជនចិន ស័ក្តិសមនឹងចំណងមិត្តភាពរវាងប្រទេសទាំងពីរដែលរឹងមាំដូចដែកថែប ហើយជាដៃគូក្នុងការកសាងសហគមន៍ដែលមានវាសនារួមគ្នា។ ថ្នាក់ដឹកនាំចិនក៏បានបញ្ជាក់ដែរថា រដ្ឋាភិបាល និងប្រជាជនចិនមានជំនឿជឿជាក់លើសមត្ថភាពខ្លួន ដើម្បីដោះស្រាយវិបត្តិនៃការរាលដាលជម្ងឺមកពីវីរុសកូរ៉ូណា ហើយនឹងអាចជំនះបានដោយជោគជ័យលើផលប៉ះពាល់ដល់សេដ្ឋកិច្ចសង្គម បណ្តាលមកពីជម្ងឺនេះ ហើយចិននឹងបន្តផ្តល់ការយកចិត្តទុកដាក់ខ្ពស់ចំពោះប្រជាជនកម្ពុជា ក៏ដូចជាជនបរទេសឯទៀតដែរ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំចិនទាំងពីររូប ក៏បានពិភាក្សាយ៉ាងទូលំទូលាយអំពីកិច្ចសហប្រតិបត្តិការទ្វេភាគីផងដែរ ។ ថ្នាក់ដឹកនាំចិន បានឯកភាពចំពោះសំណូមពររបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលស្នើជំរុញល្បឿននៃការចរចា និងឈានទៅចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិនឲ្យបានក្នុងពេលឆាប់ៗខាងមុខ ដើម្បីផ្តល់លទ្ធភាពឲ្យកម្ពុជាមានទីផ្សារកាន់តែធំសម្រាប់ផលិតផលរបស់ខ្លួន។ ម្យ៉ាងទៀត **សម្តេចតេជោ** ក៏បានបញ្ជាក់ថា កម្ពុជាកំពុងតែអនុវត្តវិធានការកែទម្រង់មុតស្រួច ដើម្បីកែលម្អបរិយាកាសធុរកិច្ចសំដៅទាក់ទាញការបណ្តាក់ទុនពីចិន និងប្រទេសឯទៀតឲ្យបានកាន់តែច្រើន ហើយត្រៀមខ្លួនទប់ទល់ផលប៉ះពាល់អវិជ្ជមាន ក្នុងករណីសហភាពអឺរ៉ុប សម្រេចចាត់វិធានការពាក់ព័ន្ធនឹងប្រព័ន្ធអនុគ្រោះពន្ធលើគ្រប់មុខទំនិញលើកលែងតែអាវុធ ( EBA ) ។

**ឯកឧត្តម នាយករដ្ឋមន្ត្រី លី ខឺឈាង** និង **ឯកឧត្តម ប្រធានាធិបតី ស៊ី ជីនពីង** បានសន្យាជំរុញឲ្យក្រុមហ៊ុនចិនបង្កើនការវិនិយោគនៅកម្ពុជា និងបន្តផ្តល់ជំនួយដល់ការអភិវឌ្ឍន៍កម្ពុជាឱ្យអស់ពីលទ្ធភាព រួមទាំងការអភិវឌ្ឍនៅក្រុងព្រះសីហនុ។ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ បិទល្បែងតាមប្រព័ន្ធអ៊ិនធឺណែត ( Online Gambling ) ទាំងស្រុង ដើម្បីចៀសវាងផលប៉ះពាល់អវិជ្ជមានដល់សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ក៏ដូចជាមុខមាត់ និងទំនាក់ទំនងកម្ពុជា-ចិន។

**សម្តេចតេជោ** និងថ្នាក់ដឹកនាំចិន បានផ្លាស់ប្តូរយោបល់ផងដែរអំពីកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌពហុភាគី និងបញ្ហាអន្តរជាតិមួយចំនួន។ ឆ្លៀតឱកាសនេះ **សម្តេចតេជោ** បានស្នើអញ្ជើញ **ឯកឧត្តម នាយករដ្ឋមន្ត្រី លី ខឺឈាង** មកចូលរួមកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣ ក្នុងខែវិច្ឆិកា ឆ្នាំ២០២០នៅភ្នំពេញ។ ជាឆ្លើយតប **ឯកឧត្តមនាយករដ្ឋមន្ត្រីចិន** បានសន្យាអញ្ជើញចូលរួមកិច្ចប្រជុំកំពូលនេះ ដោយផ្ទាល់ ៕

ថ្ងៃ សុក្រ ១៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ ២០២០